Inspire Empower Succeed

**Article**
**December 2021**

# បណ្តាញព័ត៌មានឌីជីថលនៅកម្ពុជា

បច្ចេកវិទ្យា និងនវានុវត្តន៍នៅក្នុងបណ្តាញព័ត៌មាន បានធ្វើឱ្យមានការផ្លាស់ប្តូររបៀបដែលមនុស្សទទួលព័ត៌មាន, រៀនសូត្រ, កំសាន្ត និងទំនាក់ទំនងគ្នានៅក្នុងជីវិតរស់នៅប្រចាំថ្ងៃ។ យោងតាមគេហទំព័រ mba SKOOL «**បណ្តាញព័ត៌មានឌីជីថល**» សំដៅដល់ប្រភេទបណ្តាញព័ត៌មានដែលអាចធ្វើការផ្សព្វផ្សាយខ្លឹមសារក្រោមទម្រង់ជារូបភាព, វីដេអូ, សំឡេង និងខ្លឹមសារមាតិកានានា តាមរយៈថ្នាលឌីជីថល ដូចជា ប្រព័ន្ធផ្សព្វផ្សាយអេឡិចត្រូនិក, ទូរស័ព្ទចល័ត, កុំព្យូទ័រ, ថេប្លេត, និងគេហទំព័រ ជាដើម។

ទម្រង់បណ្តាញព័ត៌មានដំបូងគេបង្អស់លើពិភពលោកត្រូវបានរកឃើញនៅទីក្រុងរ៉ូម កាលពីសម័យបុរាណ ដែលត្រូវបានចម្លងលើក្តារបន្ទះដោយដៃផ្ទាល់ ដើម្បីធ្វើការផ្សព្វផ្សាយព័ត៌មានបន្តដល់ប្រជាពលរដ្ឋ នេះបើយោងតាមគេហទំព័រ Lumen Learning។ ជាមួយនឹងការបង្កើតម៉ាស៊ីនបោះពុម្ពរបៀបដែលមនុស្សធ្វើការចែករំលែកព័ត៌មានត្រូវបានផ្លាស់ប្តូរ។ កាសែត និងទស្សនាវដ្តី ត្រូវបានផលិតនិងចែកចាយទូលំទូលាយជាងមុន នៅក្នុងសតវត្សរ៍ទី១៧។ ក្រោយមក វត្តមាននៃទូរលេខ អង្គលីលេខ និងវិទ្យុ នៅក្នុងសតវត្សរ៍ទី១៩ បានធ្វើឱ្យការចែកចាយព័ត៌មានអាចប្រព្រឹត្តទៅបានកាន់តែស្រួល ដោយប្រើរយៈពេលតែប៉ុន្មាននាទីប៉ុណ្ណោះ។ ការផ្លាស់ប្តូរយ៉ាងលឿននៃបច្ចេកវិទ្យានៅតែបន្តជះឥទ្ធិពលលើបណ្តាញព័ត៌មាន និងការផ្សព្វផ្សាយ ជាពិសេសនៅក្នុងសតវត្សរ៍ទី២០ នៅពេលទូរទស្សន៍ត្រូវបានបង្កើតឡើង ការបោះពុម្ពផ្សាយកាសែតត្រូវបានថយចុះ ហើយនៅសតវត្សរ៍ទី២១នេះ យើងចាប់ផ្តើមងាកមកប្រើប្រាស់បណ្តាញព័ត៌មានឌីជីថលដើម្បីទទួលបានព័ត៌មានផ្សេងៗ។

ភាពទូលំទូលាយនៃបណ្តាញព័ត៌មានឌីជីថល និងឥទ្ធិពលរបស់វានៅក្នុងសង្គមរស់នៅ បានបង្ហាញថាយើងកំពុងចាប់ផ្តើមយុគសម័យថ្មីនៃប្រព័ន្ធផ្សព្វផ្សាយ ដែលត្រូវបានគេស្គាល់ថាជា «**យុគសម័យព័ត៌មាន**» ឬ «**យុគសម័យឌីជីថល**» នៅក្នុងបរិបទនៃបដិវត្តន៍ឧស្សាហកម្ម។ **យុគសម័យព័ត៌មាន**បានកែប្រែបណ្តាញព័ត៌មានពីការបោះពុម្ពផ្សាយដោយប្រើប្រាស់ក្រដាស ទៅជាការផ្សព្វផ្សាយ និងបង្កើតមាតិកានៅលើថ្នាលឌីជីថល ដោយបច្ចេកវិទ្យាព័ត៌មាននេះបានអនុញ្ញាតឱ្យអ្នកសារព័ត៌មានធ្វើការប្រើប្រាស់, កែប្រែ, រក្សាទុក និងចែករំលែកព័ត៌មានទៅកាន់មនុស្សរាប់លាននាក់។ ឧបករណ៍អេឡិចត្រូនិកមួយចំនួន ដូចជា កាមេរ៉ាឌីជីថល និងដ្រូនបានជួយសម្រួលដល់អ្នកសារព័ត៌មានក្នុងការផ្តិតយករូបភាព និងវីដេអូនៅពេលវេលាជាក់ស្តែង។ មិនតែប៉ុណ្ណោះ វត្តមាន World Wide Web និងអ៊ីនធឺណិតបានផ្លាស់ប្តូរវិស័យព័ត៌មានទាំងស្រុង ដែលការផ្លាស់ប្តូរនេះមានល្បឿនលឿន ព្រមទាំងបាននាំមកនូវទម្រង់**សេដ្ឋកិច្ចថ្មីមួយដែលផ្អែកលើព័ត៌មាន** (Information-based economy)។

***«បណ្តាញព័ត៌មានឌីជីថល»*** ចែកចេញជា ៥ ប្រភេទសំខាន់ៗ រួមមាន គេហទំព័រ, កម្មវិធីទូរស័ព្ទ, បណ្តាញសង្គម, ផតខាស (Podcast) និងប្លុក (Blog)។ បណ្តាញព័ត៌មានទាំងនេះបានផ្តល់នូវអត្ថប្រយោជន៍ជាច្រើនដល់អ្នកតាមដានព័ត៌មាន ដោយពួកគេអាចទទួលបានព័ត៌មានដោយឥតគិតថ្លៃ ឬក្នុងតម្លៃសមរម្យនៅគ្រប់ពេលវេលា និងគ្រប់ទីកន្លែង តាមរយៈទូរស័ព្ទដៃ កុំព្យូទ័រ និងថេប្លេតជាដើម។ ម៉្យាងទៀត ចំពោះអ្នកសារព័ត៌មាន បណ្តាញព័ត៌មានឌីជីថលបានអនុញ្ញាតឱ្យពួកគេធ្វើការកែប្រែ ឬធ្វើបច្ចុប្បន្នភាពព័ត៌មានបានយ៉ាងលឿន និងងាយស្រួល និងអាចធ្វើអន្តរកម្មជាមួយអ្នកតាមដានព័ត៌មាននៅលើថ្នាលឌីជីថលផ្ទាល់តែម្តង។ លើសពីនេះទៀត អាជីវកម្មនានាក៏អាចធ្វើការផ្សព្វផ្សាយនូវផលិតផល ឬសេវាកម្មទៅកាន់មនុស្សជាច្រើនជុំវិញពិភពលោកបាន តាមរយៈបណ្តាញព័ត៌មានឌីជីថលទាំងនេះ។ បណ្តាញព័ត៌មានឌីជីថលមិនត្រឹមតែជួយសម្រួលដល់អ្នកតាមដានព័ត៌មាន អ្នកសារព័ត៌មាន និងអាជីវកម្មប៉ុណ្ណោះទេ តែក៏បានជួយដល់បរិស្ថានតាមរយៈការកាត់បន្ថយការប្រើប្រាស់ក្រដាស និងទឹកថ្នាំគីមីផងដែរ។



## I. ឥទ្ធិពលនៃបណ្ដាញព័ត៌មានឌីជីថលមកលើសង្គម សេដ្ឋកិច្ច

ការផ្លាស់ប្ដូរយ៉ាងលឿននៃបច្ចេកវិទ្យាបានជះឥទ្ធិពលយ៉ាងខ្លាំងលើវិស័យព័ត៌មាន ដោយការបោះពុម្ពផ្សាយកាសែតត្រូវបានថយចុះ ហើយនៅសតវត្សរ៍ទី២១នេះ យើងចាប់ផ្ដើមងាកមកប្រើប្រាស់បណ្ដាញព័ត៌មានឌីជីថលដើម្បីទទួលបានព័ត៌មានផ្សេងៗ។ បណ្ដាញព័ត៌មានឌីជីថលបានធ្វើឱ្យអ្នកសារព័ត៌មានមួយចំនួនបាត់បង់ការងារ ហើយក្រុមហ៊ុនកាសែតមួយចំនួនត្រូវបានបិទទ្វារ។ តួយ៉ាងយោងតាមគេហទំព័រ Forbes ចំណូលពីការបោះពុម្ពផ្សាយកាសែតមានចំនួនរហូតដល់ **៤៩,៩ ពាន់លានដុល្លារ** នៅឆ្នាំ២០០៥ ប៉ុន្តែចំណូលនេះបានធ្លាក់ចុះមកត្រឹមប្រមាណ **៨,៨ ពាន់លានដុល្លារ** ប៉ុណ្ណោះនៅឆ្នាំ២០២០។ មូលហេតុនៃការធ្លាក់ចុះយ៉ាងគំហុកនៃចំណូលពីការបោះផ្សាយកាសែតនេះ គឺព្រោះតែបណ្ដាញព័ត៌មានអេឡិចត្រូនិកមានការរីកលូតលាស់យ៉ាងខ្លាំង ដោយបានផ្ដល់ភាពងាយស្រួល និងរហ័សជាងបណ្ដាញព័ត៌មានបែបប្រពៃណី ដូចជា កាសែត និងទស្សនាវដ្ដី ដែលកាន់តែបាត់បង់ការគាំទ្រ។ ដូច្នេះ អាជីវកម្មបណ្ដាញព័ត៌មានបែបប្រពៃណីត្រូវធ្វើការសម្របខ្លួនជាមួយគំរូអាជីវកម្មថ្មីតាមការវិវត្តនៃបច្ចេកវិទ្យា បើពុំនោះទេអាចប្រឈមនឹងការបិទទ្វារអាជីវកម្ម។ កំឡុងពេលនៃវិបត្តិជំងឺកូវីដ-១៩នេះ អាជីវកម្មបណ្ដាញព័ត៌មានតាមបែបប្រពៃណីកាន់តែរងផលប៉ះពាល់បន្ថែមទៀត ដែលបានធ្វើឱ្យក្រុមហ៊ុនកាសែតធំៗរបស់សហរដ្ឋអាមេរិកមួយចំនួន ដូចជា The Stranger in Seattle, Vox Media និង Gannett បានបង្ខំចិត្តកាត់បន្ថយចំនួនបុគ្គលិក និងប្រាក់ខែបុគ្គលិក។ ផ្ទុយទៅវិញ បើពិនិត្យមើលអំពីតម្លៃសេដ្ឋកិច្ចរបស់បណ្ដាញព័ត៌មានឌីជីថលគឺមានការរីកចម្រើនយ៉ាងខ្លាំង ដោយក្នុងនោះចំណូលនៅក្នុងទីផ្សារបណ្ដាញព័ត៌មានឌីជីថល សម្រាប់ឆ្នាំ២០២១នេះ ត្រូវបានវាយតម្លៃថាស្ថិតនៅក្នុងរង្វង់ប្រមាណ **២៩៤ពាន់លានដុល្លារ** នេះបើយោងតាមទិន្នន័យរបស់ Statista។ ជាក់ស្ដែង បណ្ដាញព័ត៌មានឌីជីថលក៏បានជួយដល់ការបង្កើតការងារថ្មីៗនៅក្នុងវិស័យព័ត៌មាន រួមមាន អ្នកថតរូបបណ្ដាញព័ត៌មានឌីជីថល (Digital Media Photographer), អ្នកកាត់តវីដេអូ (Video Editor), អ្នកឯកទេសប្រព័ន្ធផ្សព្វផ្សាយសង្គម (Social Media Specialist), អ្នករចនាក្រាហ្វិក (Graphic Designer) និងអ្នកទីផ្សារឌីជីថល (Digital Marketer) ជាដើម។

ម្យ៉ាងទៀត ខណៈដែលបណ្ដាញព័ត៌មានឌីជីថលផ្ដល់នូវព័ត៌មានយ៉ាងទូលំទូលាយដល់ប្រជាជនជុំវិញពិភពលោក យើងសង្កេតឃើញថាបញ្ហា **«ព័ត៌មានក្លែងក្លាយ»** (Fake News) បាននិងកំពុងក្លាយជាប្រធានបទដ៏សំខាន់មួយដែលត្រូវយកចិត្តទុកដាក់។ នៅក្នុងយុគសម័យឌីជីថលនេះ មនុស្សស្ទើរតែគ្រប់គ្នាអាចក្លាយជាអ្នកសារព័ត៌មានបាន ដូច្នេះវាមានការលំបាកក្នុងការរក្សាស្តង់ដានៃសារព័ត៌មាន។ មិនតែប៉ុណ្ណោះ យោងតាមការសិក្សារបស់ MIT Sloan School of Management នៅឆ្នាំ ២០១៨ បានបង្ហាញថា**ព័ត៌មានក្លែងក្លាយ**តែងត្រូវបានគេចាប់អារម្មណ៍ច្រើនជាងព័ត៌មានពិត ដោយក្នុងនោះការសិក្សានេះបានរកឃើញថាព័ត៌មានមិនពិតត្រូវបានគេ Retweet នៅលើ Twitter លើសពីព័ត៌មានពិតប្រមាណ ៧០%។ អ្នកដែលរងផលប៉ះពាល់ខ្លាំងជាងគេពីព័ត៌មានមិនពិតគឺកុមារ ដោយពួកគេឆាប់ជឿជាក់ និងងាយស្រួលក្នុងការបញ្ឆោតព័ត៌មានជាងមនុស្សពេញវ័យ។ បច្ចុប្បន្ននេះ បណ្ដាញ

សង្គមមួយចំនួនដូចជា Facebook, Instagram និង TikTok កំពុងមានប្រជាប្រិយភាពខ្លាំងក្នុងចំណោមកុមារ ដែលជាកន្លែងងាយស្រួលក្នុងការផ្សព្វផ្សាយព័ត៌មានក្លែងក្លាយ។




## II. ឥទ្ធិពលនៃបណ្តាញព័ត៌មានឌីជីថលលើឥរិយាបថរបស់អ្នកសារព័ត៌មាន

នៅក្នុងយុគសម័យឌីជីថលនេះ បច្ចេកវិទ្យាកាន់តែឆ្លាត និងរីកចម្រើនជារៀងរាល់ថ្ងៃ ដោយបានផ្តល់នូវភាពងាយស្រួលជាច្រើន ហើយបាននិងកំពុងជំរុញធ្វើឱ្យមានការផ្លាស់ប្តូរឥរិយាបថរបស់យើងនៅក្នុងពិភពអនឡាញនេះ។ នៅក្នុងវិស័យព័ត៌មាន បច្ចេកវិទ្យាឌីជីថលបានធ្វើឱ្យមានការផ្លាស់ប្តូរយ៉ាងខ្លាំងនូវរបៀបដែលយើងបង្កើត និងទទួលព័ត៌មាន។ កាលពីពាក់កណ្តាលសតវត្សរ៍ទី ២០ បណ្តាញព័ត៌មាននៅមានចំនួនតិចតួចនៅឡើយ ដោយអ្នកតាមដានព័ត៌មានអាចជ្រើសរើសកាសែត ទស្សនាវដ្តី វិទ្យុ ឬទូរទស្សន៍ក្នុងការទទួលបានព័ត៌មាន។ ប៉ុន្តែនារយៈកាលប៉ុន្មានទសវត្សរ៍ចុងក្រោយនេះ បច្ចេកវិទ្យាបានធ្វើឱ្យមានការបង្កើតបណ្តាញថ្មីបន្ថែមជាច្រើន ដូចជា កម្មវិធីទូរស័ព្ទ និងគេហទំព័រ ជាដើម។

ក្នុងន័យនេះ ក្រុមហ៊ុនសារព័ត៌មានបានធ្វើការបង្កើតខ្លឹមសារមាតិកាលើបណ្តាញច្រើន ផ្សេងៗគ្នា ដើម្បីបំពេញតម្រូវការរបស់អតិថិជន តួយ៉ាង The New York Times មិនត្រឹមតែមានគេហទំព័រព័ត៌មានផ្ទាល់ខ្លួនប៉ុណ្ណោះទេ តែក៏បានបង្កើតផតខាសដើម្បីបំពេញតម្រូវការអ្នកចូលចិត្តស្តាប់ព័ត៌មានតាមឧករណ៍អេឡិចត្រូនិកនានា។ ទន្ទឹមនេះ ក្រុមហ៊ុនសារព័ត៌មានភាគច្រើនមានវត្តមានយ៉ាងសកម្មនៅលើបណ្តាញសង្គម ដូចជា Facebook, Twitter និងYouTube ជាដើម។

លើសពីនេះទៀត បណ្តាញព័ត៌មានឌីជីថលបានអនុញ្ញាតឱ្យអ្នកសារព័ត៌មានធ្វើអន្តរកម្មជាមួយអ្នកតាមដានព័ត៌មាន ហេតុនេះហើយ បច្ចុប្បន្ននេះ អ្នកសារព័ត៌មានតែងរកវិធីថ្មីៗក្នុងការរក្សាចំណាប់អារម្មណ៍របស់អ្នកតាមដានព័ត៌មានលើមាតិការបស់ពួកគេ ដោយក្នុងនោះអ្នកសារព័ត៌មានបានប្រើប្រាស់ Chatbot និងបង្កើតសំណួរ (Quiz) ជាដើម។ ជាក់ស្តែង The Washington Post បានបង្កើត bot នៅលើ Messenger ដោយអ្នកប្រើប្រាស់អាចធ្វើការផ្ញើសារទៅកាន់ Messenger របស់ The Washington Post ហើយBot នេះនឹងធ្វើការឆ្លើយតបជាមួយនឹងចំណងជើងព័ត៌មានថ្មីៗ។ អ្នកប្រើប្រាស់អាចចុចលើពាក្យអានបន្ថែម (Read More) ដើម្បីមើលព័ត៌មានទាំងនោះពេញលេញ។

កាលពីពេលមុន មុខងារចម្បងនៃចំណងជើងព័ត៌មាននៅតាមបណ្តាញព័ត៌មានបែបប្រពៃណី គឺផ្តល់ឱកាសឱ្យអ្នកអាន យល់ច្បាស់អំពីអ្វីដែលអត្ថបទនោះចង់បង្ហាញ។ ប៉ុន្តែនាពេលបច្ចុប្បន្ន សម្រាប់បណ្តាញព័ត៌មានឌីជីថល មុខងារចម្បងរបស់ចំណងជើងព័ត៌មានត្រូវបានផ្លាស់ប្តូរ ដោយអ្នកសារព័ត៌មានច្រើនប្រើប្រាស់ចំណងជើង ដើម្បីទាក់ទាញអ្នកអានឱ្យចូលទៅកាន់តំណ (link) ព័ត៌មាន ដែលត្រូវបានគេស្គាល់ថាជា **clickbait** ។ អ្នកសារព័ត៌មានមួយចំនួនក៏បានសរសេរបំផ្លើសចំណងជើងព័ត៌មាន ដើម្បីឱ្យអ្នកអានកាន់តែចង់ដឹងពីព័ត៌មាននោះ។



### III. ឥទ្ធិពលនៃបណ្ដាញព័ត៌មានឌីជីថលលើឥរិយាបថរបស់អ្នកតាមដានព័ត៌មាន

បច្ចេកវិទ្យាមិនត្រឹមតែធ្វើឱ្យមានការផ្លាស់ប្ដូរឥរិយាបថរបស់អ្នកសារព័ត៌មានប៉ុណ្ណោះទេ តែក៏បានផ្លាស់ប្ដូរឥរិយាបថរបស់អ្នកអានផងដែរ។ បច្ចុប្បន្ននេះ អ្នកតាមដានព័ត៌មានភាគច្រើនលែងជ្រើសរើសការទទួលព័ត៌មានតាមរយៈបណ្ដាញព័ត៌មានបែបប្រពៃណី ដូចជា កាសែត ទស្សនាវដ្ដី ទូរទស្សន៍ ឬវិទ្យុ។ ពួកគេជ្រើសរើសទទួលព័ត៌មានតាមរយៈវេបសាយ កម្មវិធីទូរស័ព្ទ ឬបណ្ដាញសង្គម ដោយហេតុថាបណ្ដាញព័ត៌មានទាំងនេះជួយឱ្យពួកគេទទួលបានព័ត៌មានគ្រប់ប្រភេទបានយ៉ាងលឿន និងងាយស្រួល។ ឧទាហរណ៍ ... តួយ៉ាង យោងតាមការស្ទង់មតិរបស់ Pew Research Center នៅឆ្នាំ ២០២១ នេះ **៣១%** នៃមនុស្សពេញវ័យនៅអាមេរិកទទួលព័ត៌មានពី Facebook, **២២%** ពី YouTube, **១៣%** ពី Twitter និង **១១%** ពី Instagram។

មិនតែប៉ុណ្ណោះ សម្រាប់បណ្ដាញព័ត៌មានបែបប្រពៃណី អ្នកសារព័ត៌មានជាអ្នកគ្រប់គ្រងនូវព័ត៌មានដែលត្រូវចេញផ្សាយ ហើយអ្នកតាមដានព័ត៌មានជាអ្នកអសកម្ម ដោយពួកគេគ្រាន់តែបានទទួលព័ត៌មានតែមិនបានធ្វើការបញ្ចេញមតិយោបល់ផ្ទាល់ខ្លួន។ ជាមួយនឹងបណ្ដាញព័ត៌មានឌីជីថល អ្នកតាមដានព័ត៌មានបានក្លាយជាអ្នកសកម្ម ដោយពួកគេមិនត្រឹមតែអាចទទួលបានព័ត៌មានទាន់ហេតុការណ៍ប៉ុណ្ណោះទេ តែក៏អាចធ្វើការចែករំលែកព័ត៌មានតាមរយៈបណ្ដាញសង្គម, ប្លុក និងផតខាសជាដើម, បញ្ចេញមតិយោបល់តាមរយៈកន្លែងបញ្ចេញមតិ និងធ្វើការពិនិត្យព័ត៌មានពីប្រភពមួយទៅប្រភពមួយទៀត មុននឹងធ្វើការជឿទុកចិត្ត។

ម្យ៉ាងទៀត បច្ចុប្បន្ននេះ អ្នកអានព័ត៌មានចូលចិត្តអត្ថបទខ្លីៗជាងអត្ថបទវែង និងស៊ីជម្រៅ។ យោងតាមគេហទំព័រ Orientation នៅឆ្នាំ២០២០ អ្នកអានព័ត៌មាននៅតាមគេហទំព័រនានាចំណាយពេលជាមធ្យមត្រឹមតែ ១៥ វិនាទីប៉ុណ្ណោះក្នុងការអាន។ បើសិនជាពួកគេមានបំណងចង់អានអត្ថបទឱ្យចប់ គឺត្រូវចំណាយពេល ២០ ទៅ ៣០% លើសពីពេលដែលពួកគេចំណាយសម្រាប់ការអានព័ត៌មាននៅលើកាសែត ឬទស្សនាវដ្ដី។ ដូច្នេះ ពួកគេចូលចិត្តអត្ថបទខ្លីៗ និងចូលចិត្តស្កេន (Scan) អត្ថបទជាងការអានយ៉ាងយកចិត្តទុកដាក់។



## IV. ករណីសិក្សា៖ បណ្ដាញព័ត៌មានឌីជីថលនៅកម្ពុជា

យោងតាមលោក **លាង ដឹលុច** នាយកប្រតិបត្តិនៃសារព័ត៌មានអេឡិចត្រូនិក Thmey Thmey ដែលបានចូលរួមជាវាគ្មិននៅក្នុងកម្មវិធី «**ជជែកពីកម្ពុជា ៤.0**» លើប្រធានបទ «**សារព័ត៌មានឌីជីថលនៅកម្ពុជា**» វិស័យសារព័ត៌មាន ក៏ដូចជាបណ្ដាញព័ត៌មានជារួមនៅប្រទេសកម្ពុជា បានចាប់ផ្ដើមវិវត្តន៍ប្រែប្រួលយ៉ាងឆាប់រហ័ស ជាមួយនឹងវត្តមាននៃបណ្ដាញអ៊ីនធឺណិត និងការប្រើប្រាស់បណ្ដាញសង្គម។ យ៉ាងណាមិញ បច្ចុប្បន្ននេះ យើងសង្កេតឃើញថាចំនួនអ្នកប្រើប្រាស់ទូរស័ព្ទដៃទំនើបនៅកម្ពុជាមានការកើនឡើងយ៉ាងខ្លាំង ដែលត្រូវបានគេស្គាល់ថាជាសម័យស្មាតហ្វូន។ ដើម្បីឆ្លើយតបនឹងការវិវត្តឥតឈប់ឈរនៃបច្ចេកវិទ្យា ក្រុមហ៊ុនសារព័ត៌មាននៅកម្ពុជាជាច្រើនបានផ្លាស់ប្ដូរពីការបោះពុម្ពផ្សាយកាសែត និងទស្សនាវដ្ដីទៅជាការផ្សព្វផ្សាយព័ត៌មានតាមរយៈបណ្ដាញព័ត៌មានឌីជីថល។

### ១. កត្តាជំរុញឱ្យបណ្ដាញព័ត៌មាននៅកម្ពុជាវិវត្តន៍ទៅជាបណ្ដាញព័ត៌មានឌីជីថល

ខាងក្រោមនេះជាកត្តាសំខាន់ៗដែលជំរុញឱ្យបណ្ដាញព័ត៌មាននៅកម្ពុជាវិវត្តន៍ទៅជាបណ្ដាញព័ត៌មានឌីជីថល រួមមាន៖

#### ➢ ការចាប់យកបច្ចេកវិទ្យារបស់ប្រជាជនកម្ពុជា

យោងតាមទិន្នន័យរបស់**និយ័តករទូរគមនាគមន៍កម្ពុជា** ចំនួនប្រជាជនប្រើប្រាស់ទូរស័ព្ទដៃនៅកម្ពុជាមានការកើនឡើងយ៉ាងឆាប់រហ័ស ដោយកើនដល់ប្រមាណជាង ២០លានលេខ នៅក្នុងឆ្នាំ២០២១នេះ (ដូចមានក្នុងក្រាហ្វិកខាងក្រោម)។



មិនតែប៉ុណ្ណោះ ចំនួនអ្នកប្រើប្រាស់អ៊ីនធឺណិតនៅកម្ពុជាក៏មានការកើនឡើងយ៉ាងខ្លាំង នារយៈកាលប៉ុន្មានឆ្នាំចុងក្រោយនេះ ដោយក្នុងនោះចំនួនអ្នកប្រើប្រាស់អ៊ីនធឺណិតអចល័ត (Fixed Internet Subscribers) កើនដល់ប្រមាណជាង ៣២ម៉ឺននាក់ និងចំនួនអ្នកប្រើប្រាស់អ៊ីនធឺណិតចល័ត (Mobile Internet Subscribers) កើនដល់ប្រមាណជាង ១៧លាន នៅក្នុងឆ្នាំ២០២១នេះ (ដូចមានក្នុងក្រាហ្វិកខាងក្រោម)។







ដូច្នេះ យើងអាចមើលឃើញពីសញ្ញាណវិជ្ជមាននៃការចាប់យកបច្ចេកវិទ្យារបស់ប្រជាពលរដ្ឋកម្ពុជា ដែលការចាប់យកនេះបានផ្លាស់ប្តូរឥរិយាបថនៃការរស់នៅរបស់ប្រជាជនយើងទាំងការសិក្សា, ការបំពេញការងារ និងការកំសាន្ត ពិសេសការទទួលព័ត៌មាន។

## ➤ ការវិវត្តនៃបច្ចេកវិទ្យា

កាលពីមុនទសវត្សរ៍ឆ្នាំ ៩០ ប្រដាប់បំពងសំឡេង (Horn) ត្រូវបានដាក់លើបង្គោលភ្លើងនៅតាមភូមិនានា ហើយប្រជាជនក្នុងសហគមន៍ស្តាប់ព័ត៌មានដែលកំពុងផ្សាយចេញពីប្រដាប់បំពងសំឡេងនេះ។ ប៉ុន្មានទសវត្សរ៍ក្រោយមក បច្ចេកវិទ្យាបានរីកចម្រើនយ៉ាងឆាប់រហ័ស ដោយបានបន្តជះឥទ្ធិពលលើវិស័យព័ត៌មាននៅកម្ពុជា ដោយក្នុងពេលនោះបណ្តាញព័ត៌មានបានវិវត្តន៍ទៅជាការបោះពុម្ពផ្សាយកាសែត និងទស្សនាវដ្តី និងការផ្សាយតាមវិទ្យុ និងទូរទស្សន៍ ហើយបច្ចុប្បន្ននេះបច្ចេកវិទ្យាក៏បានបន្តផ្លាស់ប្តូរបណ្តាញព័ត៌មានកម្ពុជាទៅជាបណ្តាញព័ត៌មានឌីជីថល ដែលអនុញ្ញាតឱ្យអ្នកអានអាចទទួលបានព័ត៌មានគ្រប់ពេលវេលា និងគ្រប់ទីកន្លែង តាមរយៈទូរស័ព្ទដៃ, កុំព្យូទ័រ និងថេប្លេតជាដើម។ ដូច្នេះ យើងអាចមើលឃើញពីការរីកចម្រើនយ៉ាងឆាប់រហ័សនៃបច្ចេកវិទ្យា ដែលតម្រូវឱ្យក្រុមហ៊ុនសារព័ត៌មាននានាចេះចាប់យកឱកាសពីបច្ចេកវិទ្យាទាំងនេះ ដើម្បីបំពេញតម្រូវការរបស់អតិថិជន។

### ឥទ្ធិពលនៃវិបត្តិជំងឺកូវីដ-១៩

វិបត្តិជំងឺកូវីដ-១៩ បានស្តែងឱ្យឃើញកាន់តែច្បាស់ពីសារៈសំខាន់ និងភាពចាំបាច់នៃការប្រើប្រាស់បច្ចេកវិទ្យា និងប្រព័ន្ធឌីជីថល។ ជាក់ស្តែង នាអំឡុងពេលនៃការឆ្លងរាលដាលជំងឺកូវីដ-១៩ យើងសង្កេតឃើញថាការប្រើបច្ចេកវិទ្យាជាជំនួយកាន់តែមានតម្រូវការខ្លាំងឡើងសម្រាប់ការបំពេញការងារ, ការរៀនសូត្រ, ការទំនាក់ទំនង និងការទទួលបានព័ត៌មាន។ មកដល់បច្ចុប្បន្ន បើទោះបីជាស្ថានភាពនៃការឆ្លងរាលដាលនៃជំងឺនេះមានសភាពប្រសើរជាងមុន តែយើងនៅតែត្រូវបន្តរៀនរស់ជាមួយកូវីដ-១៩ តាមគន្លងប្រក្រតីភាពថ្មី ដោយប្រជាជនភាគច្រើនក៏បានទម្លាប់នឹងការប្រើប្រាស់បច្ចេកវិទ្យា ដូចជាការទូទាត់តាមបែបឌីជីថល និងការទទួលព័ត៌មានតាមប្រព័ន្ធអនឡាញជាដើម។ ជាការឆ្លើយតបទៅនឹងនិន្នាការនេះ ក្រុមហ៊ុនសារព័ត៌មានជាច្រើនបានផ្លាស់ប្តូរសេវាកម្មរបស់ខ្លួន ដោយចាប់ផ្តើមផ្សព្វផ្សាយតាមបណ្តាញសង្គម ឬបង្កើតជាកម្មវិធីទូរស័ព្ទ និងគេហទំព័រព័ត៌មាន ដើម្បីបំពេញតម្រូវការរបស់អ្នកអាន។ បណ្តាញព័ត៌មានឌីជីថលនេះបានដើរតួនាទីយ៉ាងសំខាន់ក្នុងការផ្តល់នូវបច្ចុប្បន្នភាពព័ត៌មានដល់ប្រជាពលរដ្ឋពីស្ថានភាពនៃវិបត្តិជំងឺកូវីដ-១៩ និងព្រឹត្តិការណ៍សំខាន់ៗនានាបានយ៉ាងលឿន និងងាយស្រួល ដោយគ្រាន់តែធ្វើការចុចចូលគេហទំព័រ និងកម្មវិធីទូរស័ព្ទព័ត៌មានជាដើម។

## ២. ឥទ្ធិពលនៃបណ្តាញព័ត៌មានឌីជីថលលើវិស័យសារព័ត៌មាននៅកម្ពុជា

បណ្តាញព័ត៌មានឌីជីថលបានជួយសម្រួលដល់ក្រុមហ៊ុនសារព័ត៌មាននៅកម្ពុជា ដោយបច្ចុប្បន្ននេះ ក្រុមហ៊ុនសារព័ត៌មានមួយចំនួនមិនចាំបាច់មានការិយាល័យសម្រាប់ដំណើរការការងារ ហើយអាចមានបុគ្គលិកត្រឹម ២ ឬ៣នាក់ក៏បាន ដោយពួកគេអាចធ្វើការសម្ភាសន៍ ដើម្បីយកព័ត៌មានតាមរយៈប្រព័ន្ធវីដេអូអនឡាញ, ទំនាក់ទំនងការងារតាមអនឡាញ និងអាចធ្វើការផ្សព្វផ្សាយមាតិការបស់ខ្លួនតាមរយៈបណ្តាញសង្គមនានាបាន។ មិនតែប៉ុណ្ណោះ យោងតាមគេហទំព័រ Datareportal នៅដើមឆ្នាំ ២០២១ នេះ ប្រជាជនកម្ពុជាចំនួន ១២លាននាក់ ជាអ្នកប្រើប្រាស់បណ្តាញសង្គម។ ដូច្នេះ អ្នកសារព័ត៌មាននៅកម្ពុជាអាចធ្វើការផ្សព្វផ្សាយព័ត៌មានទៅកាន់មនុស្សបានកាន់តែច្រើននៅលើបណ្តាញសង្គម។ ទន្ទឹមនេះ បើយោងតាម **លោក លាង ដឺលុច** ការវិវត្តនៃបណ្តាញព័ត៌មានក៏បានធ្វើឱ្យការប្រកួតប្រជែងកាន់តែមានភាពស្រួចស្រាលរវាងអ្នកសារព័ត៌មាន ដែលចំណុចនេះក៏បានចូលរួមពង្រឹងគុណភាព និងប្រសិទ្ធភាពនៃប្រព័ន្ធផ្សព្វផ្សាយនៅកម្ពុជាផងដែរ។ តួយ៉ាង ក្រុមហ៊ុនកាសែតធ្វើការបោះពុម្ពផ្សាយកាសែតមួយថ្ងៃតែមួយច្បាប់ប៉ុណ្ណោះកាលពីពេលមុន ប៉ុន្តែបច្ចុប្បន្ននេះ ក្រុមហ៊ុនសារព័ត៌មានតម្រូវឱ្យធ្វើការចុះផ្សាយព័ត៌មានទាន់ហេតុការណ៍ជាប់ជាប្រចាំ ដោយអាចធ្វើការផ្សាយច្រើនដងនៅក្នុងមួយថ្ងៃ រួមទាំងធ្វើការផ្សាយបន្តផ្ទាល់នៅលើបណ្តាញសង្គមនានាផងដែរ។ យ៉ាងណាមិញ ជាមួយនឹងវត្តមាននៃបណ្តាញព័ត៌មានឌីជីថល យើងអាចមើលឃើញថាប្រជាជនគ្រប់រូបអាចធ្វើជាអ្នកសារព័ត៌មានបាន ដោយគ្រាន់តែធ្វើការសរសេរខ្លឹមសារ ឬបង្ហោះវីដេអូពីហេតុការណ៍នានានៅលើបណ្តាញសង្គម។ ប៉ុន្តែមនុស្សមួយចំនួនអាចឆ្លៀតឱកាសនេះបង្ហោះនូវព័ត៌មានក្លែងក្លាយ ហើយអ្នកដែលងាយរងគ្រោះជាងគេ

គឺអ្នកដែលមិនមានចំណេះអក្ខរកម្មឌីជីថល ដោយពួកគាត់អាចពិបាកថ្លឹងថ្លែងព័ត៌មានដែលគួរជឿទុកចិត្ត ឬមិនគួរជឿ។ ការចែករំលែកព័ត៌មានមិនពិតពីមនុស្សម្នាក់ទៅមនុស្សម្នាក់ទៀតពាសពេញបណ្តាញសង្គម អាចធ្វើឱ្យមានការប៉ះពាល់ដល់សង្គមទាំងមូលបាន។

## V. សន្និដ្ឋាន

ជារួម ភាពជឿនលឿននៃបច្ចេកវិទ្យាបាននិងកំពុងផ្លាស់ប្តូរជីវិតរស់នៅប្រចាំថ្ងៃរបស់យើង ដោយផ្តល់នូវអត្ថប្រយោជន៍ជាច្រើន ពិសេសជួយសម្រួលដល់ការផ្សព្វផ្សាយ និងការទទួលបានព័ត៌មាន។ ទន្ទឹមនឹងអត្ថប្រយោជន៍ទាំងនេះ ការផ្លាស់ប្តូរឥតឈប់ឈរនៃបច្ចេកវិទ្យាក៏បានបង្កើតនូវគំរូអាជីវកម្មថ្មី និងបានផ្លាស់ប្តូរឥរិយាបថរបស់អ្នកអាន ដែលតម្រូវឱ្យក្រុមហ៊ុនសារព័ត៌មានត្រូវចេះសម្របខ្លួន បើពុំនោះទេអាចនឹងត្រូវបិទទ្វារ ហើយបុគ្គលិកដែលបម្រើការនៅក្នុងវិស័យសារព័ត៌មានក៏មានភាពចាំបាច់ក្នុងការស្វែងយល់ និងចាប់យកជំនាញសមស្របបន្ថែមទៀតសម្រាប់បរិបទទីផ្សារការងារថ្មី។ យ៉ាងណាមិញ បើយើងក្រឡេកមកមើលករណីប្រទេសកម្ពុជាវិញ ការកើនឡើងនៃចំនួនអ្នកប្រើប្រាស់ទូរស័ព្ទដៃ និងអ្នកប្រើប្រាស់អ៊ីនធឺណិតបានបង្ហាញពីសញ្ញាណវិជ្ជមាននៃការចាប់យកបច្ចេកវិទ្យារបស់ប្រជាជនកម្ពុជា ហើយការប្រែប្រួលឥតឈប់ឈរនៃបច្ចេកវិទ្យា ក៏ដូចជាឥទ្ធិពលនៃវិបត្តិជំងឺកូវីដ-១៩ បានតម្រូវឱ្យក្រុមហ៊ុនសារព័ត៌មានងាកមកចាប់យកបណ្តាញព័ត៌មានឌីជីថលជាថ្នាលសម្រាប់ការផ្សព្វផ្សាយព័ត៌មានដល់សាធារណជន ដើម្បីបំពេញតាមតម្រូវការរបស់អ្នកអាន៕

## ឯកសារយោង


- សារព័ត៌មានឌីជីថលនៅកម្ពុជា, កម្មវិធី ជជែកពីកម្ពុជា ៤.០, វាគ្មិនកិត្តិយស លោក លាង ដឺលុច នាយកប្រតិបត្តិនៃសារព័ត៌មានអេឡិចត្រូនិក Thmey Thmey, ផ្សាយផ្ទាល់កាលពីថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០២១
- DIGITAL MEDIA, ចូលអានថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០២១, https://www.academia.edu/26084526/DIGITAL_MEDIA
- Digital Media Meaning, Importance, Types & Example, ចូលអានថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០២១, https://www.mbaskool.com/business-concepts/marketing-and-strategy-terms/17895-digital-media.html
- Media and Technology in Society, ចូលអានថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០២១,https://courses.lumenlearning.com/sociology/chapter/media-and-technology-in-society/
- Advantages and Disadvantages of Digital Media, ចូលអានថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០២១, https://www.myayan.com/advantages-and-disadvantages-of-digital-media
- Digital Media and Society, ចូលអានថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០២១, https://www3.weforum.org/docs/WEFUSA_DigitalMediaAndSociety_Report2016.pdf
- 7 Interesting Ways Technology is Changing Journalism and News Consumption, ចូលអានថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០២១, https://www.charlottestories.com/7-interesting-ways-technology-is-changing-journalism-and-news-consumption/
- Effective Headlines of Newspaper Articles in a Digital Environment, ចូលអានថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០២១, https://www.tandfonline.com/doi/full/10.1080/21670811.2017.1279978
- DIGITAL ARTICLES – HOW PEOPLE READ ONLINE, ចូលអានថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០២១, https://www.orientation.agency/insights/how-people-read-online
- 8 Careers in Digital Media , ចូលអានថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០២១, https://www.indeed.com/career-advice/finding-a-job/career-in-digital-media
- Majority of news consumers see "fake news" as a big problem today, ចូលអានថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០២១, https://www2.deloitte.com/us/en/insights/industry/technology/study-shows-news-consumers-consider-fake-news-a-big-problem.html
- MIT Sloan research about social media, misinformation, and elections, ចូលអានថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០២១, https://mitsloan.mit.edu/ideas-made-to-matter/mit-sloan-research-about-social-media-misinformation-and-elections
- The Importance of Media Literacy in a World Filled with Fake News, ចូលអានថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០២១, https://thejuicelearning.com/blog/media-literacy-in-world-with-fake-news/
- ចំនួនអ្នកប្រើប្រាស់អ៊ីនធឺណិត និងអ្នកប្រើប្រាស់ទូរស័ព្ទដៃ, និយ័តករទូរគមនាគមន៍កម្ពុជា, ចូលអានថ្ងៃទី២៧ ខែធ្នូ

ឆ្នាំ២០២១, *https://www.trc.gov.kh/en/internet-subcribers/*

- *Digital 2021: Cambodia*, ចូលអានថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០២១, *https://datareportal.com/reports/digital-2021-cambodia*
- *Digital Media – Worldwide, Statista Market Forecast*, ចូលអានថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០២១, *https://www.statista.com/outlook/dmo/digital-media/worldwide*

---

www.cambodia4point0.org

កម្ពុជា ៤.0 - Cambodia 4.0

cambodia_4.0

កម្ពុជា ៤.0 Cambodia 4.0

កម្ពុជា ៤.0 - Cambodia 4.0

កម្ពុជា ៤.0 - Cambodia 4.0

Cambodia 4.0 Center

Cambodia 4.0